# ទម្រង់ពាក្យវាយតម្លៃយុត្តិធម៌បរិស្ថាន

| | |
|---|---|
| **ឈ្មោះគម្រោង** | គម្រោងធន់រឹងមាំនៅឧទ្យានគីមសុន (Gibson Park Resiliency Project) |
| កាលបរិច្ឆេទនឹងដាក់ឯកសារ MEPA | ខែ ឧសភា ទី15, 2023 |
| ឈ្មោះគម្រោង | ទីក្រុងរីវៀ |
| ព័ត៌មានទំនាក់ទំនង (ឧ., អ្នកប្រឹក្សា) | ចន មិកលីស្ទើ ក្រុមហ៊ុនវិស្វកម្មមិកលីស្ទើ ម៉ារីន LLC(John McAllister, McAllister Marine Engineering, LLC) jmcallister@mcallister-eng.com , 401-859-1839 |
| គេហទំព័រសាធារណៈសម្រាប់គម្រោង ឬទីតាំងដាក់ស្តែងផ្សេងទៀត ដែលសម្ភារៈគម្រោងអាចទទួលបាន (ប្រសិនបើមាន) | RiverFront District Master Planning - City of Revere, Massachusetts |
| ក្រុង និងលេខកូដសម្រាប់គម្រោង (ប្រសិនបើដឹង) | រីវៀ 02151 |
| ប្រភេទគម្រោង* (រាយបញ្ជីទាំងអស់ដែលមាន) | ហេដ្ឋារចនាសម្ព័ន្ធឆ្នេរសមុទ្រ ការស្តារឡើងវិញនូវប្រព័ន្ធអេកូឡូស៊ី ការកម្សាន្ត ការជួសជុល ភាពធន |
| តើទីតាំងគម្រោងស្ថិតនៅក្នុងតំបន់ទំនាបទឹកជំនន់ FEMA 100 ឆ្នាំដែរឬទេ? បាទ/ទេ/ មិនដឹង | បាទ, Panels 25009C0528G និង 25009C0529G, Zone AE (elevation 10, NAVD 88), សុពលភាព 7/16/14 |
| ជាន់ស្មានការបំភាយ GHG នៃកន្លែងដែលមានលក្ខខណ្ឌ(click here for GHG Estimation tool) | 10 តោន/ឆ្នាំ. |

## ការពិពណ៌នាគម្រោង

1. ផ្តល់ការពិពណ៌នាសង្ខេបអំពីគម្រោង រួមទាំងទំហំទាំងមូលនៃទីតាំងគម្រោង និងទំហំអគារជាការ៉េម៉ែត្រ និងរចនាសម្ព័ន្ធដែលបានស្នើឡើង ប្រសិនបើដឹង។

ឧទ្យានគិបសុន (Gibson) ដែលមានទីតាំងនៅផ្លូវហេយអាវេញ្ញូ(Hayes Ave) ក្រុងរីវៀ រដ្ឋម៉ាសាឈូសេត(Massachusetts) គឺជាក្បាលដីសំខាន់ដែលការងារបានអនុវត្តលើគម្រោងនេះ ដើម្បីអនុវត្តដំណោះស្រាយផ្អែកលើធម្មជាតិ លើបញ្ហាទឹកជំនន់ដែលមានជាប់រហូត ការបំពុលបរិស្ថាន និងអភិវឌ្ឍឧទ្យានឡើងវិញឱ្យមានភាពធន់សមស្របនឹងអាកាសធាតុប្រែប្រួល។ គម្រោងនេះរួមមានសមាសភាគដូចខាងក្រោម:

ក្បាលដីឧទ្យានគីបសុន (Gibson Park) ទំហំ 6.22 អេគើ(acre)
ណុសស្ស័របូតវកប្រពភឹធីមានទំហំ (North Shore Boatworks Property) 1.187 (បន្ទាប់មកត្រូវបានគេហៅថាជា "ដីបូតវក(The Boatworks") ដែលមានទីតាំងនៅជាប់ខាងត្បូងនៃឧទ្យានគីបសុន។
គម្រោងស្នើសុំតំបន់ដែលមានប្រវែង 2,400 ហ្វីតនៃផ្នែកខាងលិចនៃផ្លូវមៀលអាវេញ្ញូ(Mills Avenue)ជាកន្លែងទំនាបទឹកជំនន់ពណ៌ខៀវប្រផេះ។

មានអាគារ 4,200 sf ដែលមានស្រាប់នៅលើទីតាំងបូតវកប្រពភឹធី (Boatworks Property) ដែលនឹងត្រូវបានអភិវឌ្ឍឡើងវិញ ប៉ុន្តែវានឹងរក្សានូវផ្ទៃដី4,200 sf ដដែល។

បញ្ហាទឹកជំនន់ត្រូវបានគេរំពឹងថានឹងកាន់តែអាក្រក់ទៅៗជាមួយនឹងការកើនឡើងកម្រិតទឹកសមុទ្រ និងចំនួនខ្យល់ព្យុះកាន់តែញឹកញាប់ និងកាន់តែខ្លាំងឡើង។ ដូច្នេះហើយ សាលាក្រុងបាននឹងកំពុងធ្វើការរៀបចំផែនការ ការរចនានិងអភិវឌ្ឍសួនសាធារណ:ឡើងវិញ និងមានភាពធន់ជាងមុន ស្របតាមផែនការមេរបស់ទីក្រុង ដោយប្រើប្រាស់ដំណោះស្រាយផ្អែកលើធម្មជាតិ។ ជាក់ស្តែង គម្រោងនេះបានបង្កើតនូវគោលដៅចំនួន4គម្រោង៖

1. ការបង្កើតភាពធន់ - ការផ្តល់ភាពធន់ដល់តំបន់ជិតខាង និងឧទ្យានខ្លួនឯង

| |
|---|
| 2. ការបម្រើសហគមន៍ ƒ<br>អនុញ្ញាតឱ្យមានសកម្មភាពប្រើប្រាស់ផ្សេងៗដល់អ្នកប្រើប្រាស់ទាំងអស់នៅសហគមន៍។<br>3. ដោះស្រាយជំនន់ទឹកភ្លៀងជាប្រវត្តិសាស្រ្ត ƒ<br>ផ្តល់ដំណោះស្រាយសម្រាប់ការជន់លិចដោយជំនន់ទឹកជាប្រវត្តិសាស្រ្តដែលកើតឡើងនៅភាគខាងជើងនតំបន់មាត់ទន្លេ។<br>4. ការជួសជុលដីដែលរងផលប៉ះពាល់ពីកាកសំណល់ពីសកម្មភាពឧស្សាហកម្មនៅណុសស្ស័របូតវក ប្រពភីធីចាស់(North Shore Boatworks)។<br>គោលដៅរបស់គម្រោងឧឡានគឺបសុនគឺដើម្បីផ្តល់នូវភាពធន និងធម្មជាតិរបស់ដីនិងទន្លេ ផ្តល់កន្លែងស្តុកទឹកភ្លៀងក្រៅបណ្តាញក្រោមដី និងដើម្បីបង្កើតកន្លែងគ្រប់គ្រងទឹកភ្លៀងថ្មី ដើម្បីជួយកាត់បន្ថយដល់ការជន់លិចក្នុងតំបន់ ហើយក៏អាចប្រើតំបន់នេះជាកន្លែងរកម្សាន្តដ៏ល្អប្រសើរដែរ។ |
| 2. រាយបញ្ជីកម្រិតពិនិត្យ MEPA ដែលពាក់ព័ន្ធ (301 CMR 11.03) (ប្រសិនបើដឹង)<br>3(b)1a – ការផ្លាស់ប្តូរឆ្នេរខ្សាច់ របាំងឆ្នេរ ឬច្រាំងសមុទ្រ<br>3(b)1c - ការផ្លាស់ប្តូរ 1,000 sf ឬច្រើនជាងនេះនៃបឹងអំបិល ឬតំបន់ទឹកដែលលេចធ្លោ<br>3(b)1d - ការផ្លាស់ប្តូរ 5,000 sf ឬច្រើនជាងនេះនៃតំបន់អំណោយផលដែលមានព្រំប្រទល់ ឬដាច់ស្រយាល<br>១១(ខ)- គម្រោងណាមួយនៅក្នុង ACEC ដែលបានកំណត់ លុះត្រាតែគម្រោងមានលំនៅឋានគ្រួសារតែមួយ |
| 3. រាយបញ្ជីរដ្ឋដែលជាប់ពាក់ព័ន្ធទាំងអស់ ត្រូវមានការអនុញ្ញាតពីអជ្ញាធរក្នុងតំបន់ និងសហព័ន្ធសម្រាប់គម្រោង (ប្រសិនបើដឹង)<br>សេចក្តីជូនដំណឹងអំពីចេតនា / លំដាប់នៃលក្ខខណ្ឌនៅក្រោមច្បាប់ការពារតំបន់ដីសើម ជំពូកទី 91 អាជ្ញាប័ណ្ណ/ការអនុញ្ញាត លិខិតអនុញ្ញាតរបស់ USACE ការត្រួតពិនិត្យផែនការទីក្រុងរីវៀ (Wetlands Protection Act, Chapter 91 License/Permit, USACE Permit, City of Revere Site Plan Review) |
| 4. កំណត់ចំនួនប្រជាជន និងលក្ខណៈរបស់ EJ (ជនជាតិភាគតិច ប្រាក់ចំណូល គំលាតភាសាអង់គ្លេស) ក្នុងចម្ងាយ 5 ម៉ាយពីតំបន់គម្រោង (អាចភ្ជាប់ផែនទីកំណត់ទីតាំង5ម៉ាយពី EJ Maps Viewer ជំនួសឱ្យការប៉ាន់ស្មាន)<br>ជនជាតិភាគតិច ប្រាក់ចំណូល ជនជាតិភាគតិច និងប្រាក់ចំណូល ជនជាតិភាគតិចនិងគំលាតភាសាអង់គ្លេស ប្រាក់ចំណូល និង គំលាតភាសាអង់គ្លេសនិងប្រាក់ចំណូលជនជាតិភាគតិច និងគំលាតភាសាអង់គ្លេស |
| 5. កំណត់អត្តសញ្ញាណក្រុង ឬការជំរឿនណាមួយដែលបំពេញតាម "លក្ខណៈវិនិច្ឆ័យសុខភាពដែលងាយរងគ្រោះរបស់EJ " ដោយប្រើឧបករណ៍ DPH EJ ដែលមានទីតាំងនៅទាំងមូល ឬមួយផ្នែកក្នុងរង្វង់ 1ម៉ាយនៃទីតាំងគម្រោងនៅក្រុងរីវៀ លីន និងសាយគុស (Revere, Lynn, Saugus)។ |

| |
|---|
| 5. កំណត់ផលប៉ះពាល់បរិស្ថាន និងសុខភាពសាធារណៈរយៈពេលខ្លី និងរយៈពេលវែងដែលអាចប៉ះពាល់ដល់ប្រជាជន EJ និងការកាត់បន្ថយការប៉ះពាល់ណាមួយ។ វានឹងមានផលប៉ះពាល់ពេលខ្លីនៃការបំពុលសំឡេងពីសកម្មភាពសំណង់ (ម៉ោងធ្វើការនឹងត្រូវបានកំណត់) និងអាចមានការបិទផ្លូវបណ្តោះអាសន្ន (នឹងមានផ្តល់ជូនផ្លូវវាង)។ ផលប៉ះពាល់រយៈពេលវែងនឹងមានភាពវិជ្ជមានស្ទើរតែទាំងអស់ រួមទាំងការជួសជុលសំណង់អគារកខ្វក់ ការផ្តល់ជូនការការពារទឹកជំនន់ដល់សង្កាត់រីវើសាយ(Riverside) ការផ្តល់កន្លែងសម្រាប់ការកម្សាន្តកាន់តែច្រើន និងមានទឹកស្អាតអាចប្រើប្រាស់បាន។ |
| 6. កំណត់អត្ថប្រយោជន៍គម្រោង រួមទាំង "អត្ថប្រយោជន៍បរិស្ថាន" ដូចដែលបានកំណត់ក្នុង 301 CMR 11.02 ដែលអាចធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌបរិស្ថាន ឬសុខភាពសាធារណៈរបស់ប្រជាជន EJ ។ អត្ថប្រយោជន៍ផ្នែកបរិស្ថាននៃគម្រោងនេះ រួមមានការពង្រីក និងបង្កើនការកម្សាន្តសាធារណៈ និងទីធ្លាបើកចំហ ផ្តល់សិទ្ធិចូលទៅកាន់ទន្លេផាញ (River Pines) ផ្តល់ការព្យាបាលគុណភាពទឹកភ្លៀង ដើម្បីបង្កើនគុណភាពទឹកនៅក្នុងទន្លេផាញ និងការកែលម្អបរិស្ថាននៃសំនង់អគារ។ |
| 7. ពិពណ៌នាអំពីរបៀបដែលសហគមន៍អាចស្នើសុំការប្រជុំដើម្បីពិភាក្សាអំពីគម្រោង និងរបៀបដែលសហគមន៍អាចស្នើសុំសេវាបកប្រែភាសាផ្ទាល់មាត់នៅឯកិច្ចប្រជុំ។ បញ្ជាក់ពីរបៀបស្នើសុំកន្លែងស្នាក់នៅផ្សេងទៀត រួមទាំងការប្រជុំបន្ទាប់ពីម៉ោងធ្វើការ និងនៅជិតកន្លែងដឹកជញ្ជូនអ្នកដំណើរសាធារណៈ។ ទីក្រុងរីវៀបានធ្វើសវនាការ និងកិច្ចប្រជុំសាធារណៈជាច្រើនដងចាប់តាំងពីឆ្នាំ2020 តាំងពីអគម្រោងនេះបានដំណើរការ។ នេះរួមបញ្ចូលទាំងការប្រជុំចំនួន4ដងក្នុងឆ្នាំ2020 ដើម្បីកំណត់គោលដៅ និងបំណងប្រាថ្នារបស់សហគមន៍ និងរៀបចំផែនការមេសម្រាប់ស្រុករីវើហ្វ្រន់(Riverfront) ។ បន្ទាប់មកសាលាក្រុងបានបើកកិច្ចប្រជុំសាធារណៈចំនួន3ដងបន្ថែមទៀតនៅឆ្នាំ2022 ដើម្បីពិភាក្សាបន្ថែមអំពីការ អភិវឌ្ឍរចនាបថគម្រោង គោលដៅ និងស្នើសុំមតិកែលម្អ និងមតិចូលរួមផ្សេងទៀត។ សំណើសុំព័ត៌មានបន្ថែមអាចធ្វើទៅកាន់ Elle Baker, Open Space and Environmental Planner នៅការិល័យរៀបចំផែនការនិងការអភិវឌ្ឍទីក្រុងរីវៀ(Revere's Office of Planning and Development, ebaker@revere.org) |